# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទថា ព្រះពុទ្ធពុំមែនជាទស្សនវិទូ ដូចទស្សនវិទូក្នុងលោកឡើយ

web site: hoksavann.org

ថ្ងៃទី២៣ មេសា ២០០៦

ការបញ្ចូលព្រះពុទ្ធជាទស្សនវិទូ (philosophe) ហើយពាក្យប្រៀនប្រដៅរបស់ព្រះអង្គជាទស្សនវិជ្ជា (philosophy) ក្នុងចំណោមទស្សនវិទូទាំងឡាយក្នុងលោកពុំត្រឹមត្រូវឡើយ ព្រោះព្រះពុទ្ធត្រាស់ដឹង (Enlightenment) នូវអារិយសច្ច (Noble truth) ជាធម៌ពិតសំរាប់រំដោះមនុស្សសត្វដែលប្រតិបត្តិតាមឲ្យចាកទុក្ខ ហើយព្រះអង្គមានព្រះទ័យបរិសុទ្ធផុតចាកគ្រឿងសៅហ្មងគ្រប់យ៉ាងហើយ ដែលមានលក្ខណ:ផ្ទុយអំពីការរកឃើញធម្មតារបស់ទស្សនវិទូទាំងឡាយក្នុងលោក ។ ពាក្យថា ទស្សនវិជ្ជាជាចំណេះដែលកើតពីការរកឃើញ ឬការយល់ឃើញរបស់ទស្សនវិទូទាំងនោះមានពីរបទគឺ ទស្សន:មួយបទ និងវិជ្ជាមួយបទប្រែថា វិជ្ជាអំពីទស្សន: (Point of view) គឺជាវិជ្ជាសិក្សាអំពីទស្សន: ឬមតិយោបល់ផ្សេងៗរបស់អ្នកប្រាជ្ញទាំងឡាយជាទស្សនវិជ្ជាក្នុងលោក ។ ពាក្យថាទស្សនវិជ្ជានេះ គេឲ្យអត្ថន័យម៉្យាងទៀតថា ការស្រឡាញ់គតិបណ្ឌិត (love of wisdom) ។ ទស្សន:នេះមានបទវិគ្គហ:ថា ទិដ្ឋិន្តិ ទស្សនំ ប្រែថាទស្សន:គឺទិដ្ឋិនេះឯង ។ ក្នុងបាលីព្រះពុទ្ធសាសនា បើឃើញពាក្យថា ទិដ្ឋិ គឺបានដល់មិច្ឆាទិដ្ឋិ ដូចធម៌នៅក្នុងអាសវ:៤យ៉ាងគឺ ទិដ្ឋាសវ: ប្រែថា អាសវ:គ្រឿងដេកត្រាំ គឺទិដ្ឋិការយល់ខុស ។ ដូច្នេះទស្សនវិជ្ជាដែលកើតអំពីគំនិតទស្សនវិទូនោះ នៅមានគំនិតយល់ខុស ពុំអាចប្រៀបផ្ទៀបការត្រាស់ដឹងរបស់ព្រះពុទ្ធបានឡើយ ។ ពាក្យថា សម្មាទិដ្ឋិ ប្រែថាការយល់ត្រូវ (Right Understanding) ដោយបន្ថែមសម្មានៅខាងដើមទិដ្ឋិ ។ ទស្សនវិជ្ជា គឺជាការបញ្ចេញមតិយោបល់របស់មនុស្សបុថុជ្ជន ដែលហៅថាទស្សនវិទូ ដោយពុំបានអប់រំចិត្តឲ្យបានបរិសុទ្ធដូចព្រះពុទ្ធជាម្ចាស់ឡើយ ។ មូលដ្ឋាននៃទស្សនវិជ្ជា គឺសិក្សាអំពីសង្គមវិទ្យា (Sociology), ចិត្តវិទ្យា (Psychology) និងកត្តវិជ្ជា (Logic) ។ ទស្សនវិទូសម័យបុរាណនៅក្រិក ដូច

លោកផ្លាតុង លោកសូក្រាត លោកអារិស្តូត នៅសម័យកណ្តាលនាប្រទេសបារាំង ដូចលោកដេកាត, លោកពីតាហ្គ័រ នៅអាល្លឺម៉ង់ដូចលោក Hengel លោក Openhaver លោក Karl Max ជាដើម អស់លោកទាំងនោះ លោកខ្លះមានគំនិតជាទេវនិយម ខ្លះជាសម្ភារនិយម គ្រាន់តែបញ្ចេញជាទ្រឹស្តីតាមការយល់ឃើញរបស់ខ្លួន ដោយពុំបានអប់រំកាយវាចាចិត្ត ឲ្យបានបរិសុទ្ធឡើយ ។ មានទស្សនវិទូខ្លះ ដូចលោក Karl Max មេបង្កើតទ្រឹស្តីកុម្មុយនិស្ត បានបញ្ចេញទស្សនៈធ្វើឲ្យពិភពលោកមានទំនាស់គ្នា បង្កើតជាសង្គ្រាមបង្ហូរឈាមគ្នាស្លាប់រាប់រយលាននាក់ ដោយសារទស្សនវិទូមិច្ឆាទិដ្ឋិនេះឯង ។ ចំណែកព្រះពុទ្ធជាម្ចាស់វិញ ព្រះអង្គបានអប់រំព្រះទ័យព្រះអង្គឲ្យដល់នូវភាពបរិសុទ្ធ ទើបប្រៀនប្រដៅមនុស្សសត្វជាក្រោយមានប្រៀនប្រដៅមិនឲ្យធ្វើបាបបៀតបៀនគ្នាជាដើម ។ ដូចនេះបញ្ជាក់ថា ទស្សនវិទូទាំងនោះពុំអាចយកមកប្រៀបធៀបនឹងព្រះពុទ្ធជាម្ចាស់ ដែលជាបុគ្គលបរិសុទ្ធបានឡើយ ទាំងព្រះធម៌ដែលព្រះអង្គសំដែង ក៏ជាព្រះធម៌បរិសុទ្ធ ពុំមែនជាធម៌ធ្វើឲ្យអ្នកប្រព្រឹត្តតាមមានទុក្ខ បង្កសេចក្តីទុក្ខសោកដល់សង្គមមនុស្ស ដូចជាទស្សវិទូខ្លះឡើយ ។

ការត្រាស់ដឹងធម៌របស់ព្រះពុទ្ធ និងការរកឃើញរបស់ទស្សនវិទូនូវអ្វីមួយមានលក្ខណៈខុសគ្នា គឺទស្សវិទូក្នុងលោកបានដឹងបានយល់អ្វីមួយកើតឡើង ដោយការពិសោធន៍ធម្មតា តាមវិញ្ញាណទាំង៥គឺ ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ពុំមានបញ្ញាជាន់ខ្ពស់ផ្នែកលោកុត្តរបញ្ញាដឹងរឿងពិតឡើយ ។ ចំណែកព្រះពុទ្ធព្រះបរមគ្រូវិញ បានទទួលអារម្មណ៍តាមអាយតនៈនោះដែរ ប៉ុន្តែមានញាណមួយសំរាប់ដឹងរឿងពិត គឺវិបស្សនាញាណ ទុកដូចជាអតិសុខុម-ទស្សន៍ (microscope) ជាប្រដាប់មួយបែបដែលក្រុមវិទ្យាសាស្រ្តយកទៅឆ្លុះមើលរបស់ដែលល្អិតបំផុត ដែលមើលនឹងភ្នែកធម្មតាពុំឃើញ ។ គឺព្រះអង្គមានញាណទស្សនៈ ដែលញែកជាពីរបទ គឺញាណនិងទស្សនៈ ។ ទស្សនៈគឺការដឹងតាមវិញ្ញា-ណទាំង៥ ឯញាណគឺប្រាជ្ញាដឹងរឿងពិត ឧទាហរណ៍ដូចការឃើញរូបដែលមនុស្សធម្មតាឃើញរូប ថាល្អថាស្អាតដូចជារូបមនុស្ស ប៉ុន្តែបើលើយកអាការៈ៣២មានសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម មកពិនិត្យពិចារណាតាមញាណនិងទស្សនៈឃើញថាពុំស្អាតពុំល្អឡើយ គឺចេញផុតអំពីជំនឿដែលពឹងផ្អែក តែទៅលើអាយតនៈទាំង៥គឺ ភ្នែក ត្រចៀក ច្រមុះ អណ្តាត និងកាយ ។ ដូច្នេះព្រះពុទ្ធគេពុំអាចហៅព្រះអង្គថាទស្សនវិទូបានទេ ព្រោះព្រះអង្គជាអ្នកត្រាស់ដឹងដោយប្រពៃ គឺសម្មាសម្ពុទ្ធោ ព្រះអង្គមានព្រះនាមថា ពុទ្ធោ ប្រែថា ការភ្ញាក់រលឹកអំពីអវិជ្ជា ហើយត្រាស់ដឹងនូវអរិយសច្ច៤ (four noble truth), ព្រះនាមអរហំ ប្រែថាការឆ្ងាយចាកសឹកសត្រូវពោលគឺកិលេសជាដើម ។ ក្នុងន័យនេះ គេមិនត្រូវបញ្ចូលព្រះពុទ្ធ ឲ្យនៅក្នុងចំណោមទស្សនវិទូទាំងនោះទេ ព្រោះព្រះពុទ្ធជាអរិយបុគ្គល ចំណែកទស្សវិទូទាំងនោះ ជាបុថុជ្ជនបុគ្គល ។ មួយទៀត បើគេបន្ថែមពាក្យឲ្យខ្ពស់ជាងនេះថា ព្រះពុទ្ធជាអភិទស្ស

នវិទូក៏រឹតតែមិនបានទៅទៀត ព្រោះពាក្យថាអភិប្រែថា ក្រៃលែង គឺព្រះពុទ្ធជាទស្សនវិទូដ៏ក្រៃលែង បានន័យថា ព្រះពុទ្ធជាទស្សវិទូយល់ខុសក្រៃលែង ជាងទស្សនវិទូដែលយល់ខុសដទៃទៀត ។ ប៉ុន្តែគេអាចប្រើពាក្យថា ព្រះពុទ្ធជាញាណទស្សនវិទូ គឺត្រូវបញ្ចូលពាក្យថា ញាណ ដែលជាតួបញ្ញាមួយទៀតនៅខាងដើមពាក្យទស្សនវិទូ ដែលប្រែថា ព្រះពុទ្ធជ្រាបនូវលោក ដោយពាណនិងទស្សនៈ ទើបត្រឹមត្រូវព្រោះមានញាណជាតួបញ្ញានៅក្នុងនោះ ។ ក្រៅពីញាណទស្សនវិទូ នៅក្នុងពុទ្ធគុណ គេហៅព្រះអង្គថា លោកវិទូ ដែលប្រែថាអ្នកត្រាស់ដឹងនូវលោក គឺត្រាស់ដឹងសត្តលោក របស់មានវិញ្ញាណ, សង្ខារលោក របស់គ្មានវិញ្ញាណ និងឱកាសលោករចនាសម្ពន្ធទំនាក់ទំនងគ្នា ។ ពាក្យថាត្រាស់ដឹងរបស់ព្រះពុទ្ធនិងការរកឃើញរបស់ទស្សនវិទូ ឬអ្នកវិទ្យាសាស្ត្រមានលក្ខណៈផ្សេងគ្នា គឺការត្រាស់ដឹងរបស់ព្រះពុទ្ធកើតឡើងពីការពិសោធផ្លូវចិត្ត តាមមគ្គប្រកបដោយអង្គ៨ រួមឲ្យខ្ចីបានដល់សីលសមាធិបញ្ញា ទើបជ្រាបការពិតនូវសង្ខារមានខន្ធ៥ជាដើម ដែលប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ។ ដោយព្រះអង្គមានញាណនិងទស្សនៈ ជ្រាបរឿងពិតនេះហើយទើបធ្វើឲ្យអវិជ្ជា តណ្ហា ឧបាទាន និងកម្មនៃព្រះអង្គអស់ទៅ សេចក្តីទុក្ខមានជាតិទុក្ខជាដើមក៏ត្រូវរលត់ ។ ឯក្រុមទស្សនវិទូនិងអ្នកវិទ្យាសាស្ត្របានស្រាវជ្រាវរកការពិតដោយពឹងផ្អែកទៅលើអាយតនៈតាំង៥និងឧបករណ៍ជាសម្ភារៈ សំរាប់ធ្វើការពិសោធន៍ អាចរកឃើញការពិតខ្លះជាលោកិយសច្ច សំរាប់សំរួលការរស់នៅរបស់សង្គមមនុស្សឲ្យបានសុខស្រួល ប៉ុន្តែអ្នកទស្សនវិទូនិងអ្នកវិទ្យាសាស្ត្រមួយប្រភេទទៀតរកឃើញនិងផលិតសម្ភារៈ សំរាប់សម្លាប់មនុស្សដូចជាគ្រឿងសាស្ត្រាវុធ គ្រាប់បែកបរមាណូប្រល័យលោកជាដើម ចំណែកព្រះពុទ្ធរកឃើញនិងសំដែងព្រះធម៌ដើម្បីរំលត់ទុក្ខរបស់មនុស្សសត្វតែម៉្យាងប៉ុណ្ណោះ ។៚